# ផ្នែកទី I ( iii )

# ផ្លាកសញ្ញាបង្ហាញសិទ្ធិអាទិភាព

## Priority Signs

ផ្លាកសញ្ញាបង្ហាញពីសិទ្ធិអាទិភាព មានទ្រង់ទ្រាយផ្សេងៗគ្នា ទៅតាមប្រភេទសញ្ញានិមួយៗ ដូចជាសញ្ញា " **ឈប់** " (STOP) មានរាងជាអដ្ឋកោណនិយត័ ដែលមានជាយពណ៌សពទ្ធ័ជុំវិញ ផ្ទៃពណ៌ក្រហម អក្សរពណ៌ស ។ សញ្ញា " **ផ្តល់សិទ្ធិអាទិភាពអោយគេ** " (GIVE WAY) មានរាងជាត្រីកោណសមង្ស័ ដែលមានកំពូលមួយចុះក្រោម មានស៊ុំពីរជាន់ ស៊ុំខាងក្រៅពណ៌សហើយស្តើង ឯស៊ុំខាងក្នុងពណ៌ក្រហមហើយក្រាស់ និងផ្ទៃខាងក្នុងពណ៌ស... ។ល។

ផ្លាកសញ្ញាប្រភេទនេះសំរាប់ប្រាប់អ្នកបើកបរអោយបានដឹងពី សិទ្ធិអាទិភាពរបស់ខ្លួន នៅពេលមានផ្លូវតូចចង្អៀត ផ្លូវប្រសព្វ ឬ ផ្លូវរថភ្លើងឆ្លងកាត់ ។

# ផ្នែកទី I ( iii ) : ផ្លាកសញ្ញាបង្ហាញសិទ្ធិអាទិភាព ( Priority Signs )




**ឈប់ (នៅត្រង់ផ្លូវប្រសព្វ)**

STOP ( at Intersection )

**លេខកូដ : PW03-R3-01**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវបាត់សិទ្ធិ ។ អ្នកបើកបរត្រូវឈប់ទោះបីមាន ឬ គ្មានយានជំនិះផ្សេងទៀត ឆ្លងកាត់នៅខាងមុខក៏ដោយ។ អ្នកបើកបរអាចបន្តដំណើរទៅមុខបានលុះត្រាតែផ្លូវដែលត្រូវឆ្លងកាត់នោះទំនេរ។

---



**ផ្តល់សិទ្ធិអាទិភាពអោយគេ (នៅត្រង់ផ្លូវប្រសព្វ)**

GIVE WAY ( at Intersection )

**លេខកូដ : PW03-R3-02**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវបាត់សិទ្ធិ ។ អ្នកបើកបរត្រូវតែបន្ថយល្បឿន បើសិនផ្លូវទំនេរ អាចឆ្លងកាត់បាន ។ បើផ្លូវមិនទំនេរ អ្នកបើកបរត្រូវឈប់រង់ចាំរហូត ដល់ផ្លូវទំនេរ ទើបអាចបន្តដំណើរបាន ។

---



**ផ្តល់សិទ្ធិអាទិភាពអោយគេ ( នៅរង្វង់មូល )**

GIVE WAY ( at Roundabout )

**លេខកូដ : PW03-R3-03**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវបាត់សិទ្ធិ ។ អ្នកបើកបរត្រូវតែបន្ថយល្បឿន ឬ ឈប់ ដើម្បីផ្តល់សិទ្ធិអោយយាននៅក្នុងផ្លូវរង្វង់មូលទៅមុន ។

---



**ផ្លូវធំមានសិទ្ធិ**

PRIORITY ROAD ( PRIORITY AT THE FIRST JUNCTION )

**លេខកូដ : PW03-R3-04**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវធំ មានផ្លូវតូចឆ្លងកាត់នៅខាងមុខ ។



**ផ្លូវសំខាន់មានសិទ្ធិ**

MAIN ROAD

**លេខកូដ : PW03-R3-05**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវសំខាន់ មានសិទ្ធិអាទិភាព លើផ្លូវច្រើនដែលត្រូវឆ្លងកាត់នៅខាងមុខ ។

---



**ចប់ ផ្លូវសំខាន់មានសិទ្ធិ**

END OF MAIN ROAD

**លេខកូដ : PW03-R3-06**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់ បញ្ចប់ផ្លូវសំខាន់មានសិទ្ធិ ។

---



**ផ្តល់សិទ្ធិអាទិភាពអោយយានមកពីទិសផ្ទុយ**

GIVE WAY TO ALL TRAFFIC FROM
THE OPPOSITE DIRECTION

**លេខកូដ : PW03-R3-07**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវធំ រួមតូច នៅខាងមុខអាចធ្វើចរាចរបានតែមួយជួរ ។ អ្នកបើកបរលើកំណាត់ផ្លូវដែលមានសញ្ញានេះ ត្រូវផ្តល់សិទ្ធិអាទិភាព អោយយាន មកពីទិសផ្ទុយទៅមុន ។

---



**មានសិទ្ធិអាទិភាពលើយានមកពីទិសផ្ទុយ**

PRIORITY OVER ALL TRAFFIC FROM
THE OPPOSITE DIRECTION

**លេខកូដ : PW03-R3-08**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ផ្លូវធំ រួមតូច នៅខាងមុខអាចធ្វើចរាចរបានតែមួយជួរ ។ អ្នកបើកបរលើកំណាត់ផ្លូវដែលមានសញ្ញានេះ មានសិទ្ធិអាទិភាព លើយានមកពីទិសផ្ទុយ ។



**មានផ្លូវរថភ្លើងឆ្លងកាត់ ( មួយខ្សែ )**

RAILWAY CROSSING ( ONE TRACK )

**លេខកូដ : PW03-R3-09**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ មានផ្លូវរថភ្លើងចំនួនមួយខ្សែឆ្លងកាត់នៅខាងមុខ ។ អ្នកបើកបរត្រូវទុកសិទ្ធិអាទិភាព អោយរថភ្លើងឆ្លងកាត់មុន ។

---



**មានផ្លូវរថភ្លើងឆ្លងកាត់ ( ពីរឬច្រើនខ្សែ )**

RAILWAY CROSSING ( TWO OR MORE TRACKS )

**លេខកូដ : PW03-R3-10**

**ខ្លឹមសារ :** សញ្ញានេះ សំរាប់សំគាល់ មានផ្លូវរថភ្លើងចំនួនពីរ ឬ ច្រើនខ្សែ ឆ្លងកាត់នៅខាងមុខ។ អ្នកបើកបរត្រូវទុកសិទ្ធិអាទិភាព អោយរថភ្លើងឆ្លងកាត់មុន។